## របាយការណ៍អភិវឌ្ឍន៍មនុស្ស ក្នុងតំបន់ឆ្នាំ២០២៤

# ការបង្កើតអនាគតរបស់យើង៖ ទិសដៅថ្មីសម្រាប់ការអភិវឌ្ឍមនុស្ស ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក

*ផ្តោតលើកម្ពុជា*

# ទិដ្ឋភាពទូទៅ

**ការអភិវឌ្ឍមនុស្ស គឺការផ្តោតលើមនុស្ស ផ្តោតលើការពង្រីកឱកាស សេរីភាព និងជម្រើសរបស់ពួកគេ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់ពួកគេ។** មនុស្ស និងសហគមន៍ មិនគួរជាអ្នកទទួលផលអសកម្មពីការអភិវឌ្ឍនោះទេ ប៉ុន្តែជាភ្នាក់ងារសកម្មដែលអាចចូលរួមយ៉ាងពេញលេញនៅក្នុងជីវិតសេដ្ឋកិច្ច សង្គម និងនយោបាយ និងនៅក្នុងការកសាងសន្តិសុខមនុស្ស។

**នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដំណើរអភិវឌ្ឍន៍មនុស្ស បានក្លាយជារឿងនិទានរៀបរាប់អំពីវឌ្ឍនភាព ភាពខុសគ្នា និងបញ្ហារំខាន។** អ្វីដែលធ្វើឱ្យព្រួយបារម្ភគឺថា តំបន់នេះមិនស្ថិតនៅលើគន្លងឆ្ពោះទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពណាមួយនោះទេ ហើយមនុស្សរាប់លាននាក់រស់នៅក្នុងស្ថានភាពជីវិតមិនច្បាស់លាស់ ជាមួយនឹងការគំរាមកំហែងជាច្រើនដល់សន្តិសុខ សង្គម នយោបាយ និងបរិស្ថានរបស់ពួកគេ ថែមទៀតផង។ ជាមួយគ្នានេះ ស្ថានភាពបច្ចុប្បន្ន កំពុងតែពិបាកឡើងៗ នៅក្នុងទិដ្ឋភាពជាច្រើន។តំបន់នេះ កំពុងប្រឈមនឹងការគំរាមកំហែងដែលមានស្រាប់ ដូចជា ការប្រែប្រួលអាកាសធាតុ និងបម្រែបម្រួលបរិយាកាស បច្ចេកវិទ្យា និងពាណិជ្ជកម្ម ដែលអាចរាំងស្ទះដល់កំណើនសេដ្ឋកិច្ច និងការបង្កើតការងារ។ វាក៏ប្រឈមផងដែរនឹងហានិភ័យដែលកំពុងកើនឡើងទៅលើការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព កើតចេញពីការធ្លាក់ចុះលទ្ធិប្រជាធិបតេយ្យ និងស្ថាប័នជាតិ និងការកើនឡើងមតិសាធារណៈដែលមានការបែកខ្ញែក ។

**ដើម្បីពង្រឹងការអភិវឌ្ឍមនុស្សឡើងវិញ នៅក្នុងទិដ្ឋភាពអភិវឌ្ឍ ដ៏ច្របូកច្របល់** របាយការណ៍អភិវឌ្ឍន៍មនុស្ស ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្នាំ២០២៤ **ស្នើឡើងនូវទិសដៅថ្មីៗ**។ តាមរយៈការ កសាងលើភាពជោគជ័យក្នុងតំបន់នាពេលកន្លងមក ការបង្កើតអនាគតរបស់យើង កំណត់ផ្លូវដើរជាក់ស្តែង និងតស៊ូមតិឱ្យមានអភិក្រមមួយផ្អែកលើសរសរស្តម្ភបី៖ ការបញ្ជ្រាបការអភិវឌ្ឍមនុស្ស, ការពិចារណាឡើងវិញនូវយុទ្ធសាស្ត្រកំណើន និងការធ្វើឱ្យមានការផ្លាស់ប្តូរ។

## ការអភិវឌ្ឍមនុស្សនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិកបានក្លាយជារឿងនិទានរៀបរាប់អំពីវឌ្ឍនភាព ភាពខុសគ្នា និងបញ្ហារំខាន

**តំបន់នេះបានស្ថិតនៅជួរមុខនៃការប្រែប្រួលសេដ្ឋកិច្ចជាច្រើន។** ការប្រែប្រួលសេដ្ឋកិច្ចទាំងនេះ អាចតាមដានបាន ដោយត្រឡប់ទៅមើលបទពិសោធន៍ដំបូងនៃឧស្សាហូបនីយកម្មដឹកនាំដោយការនាំចេញ របស់ប្រទេសជប៉ុន ដែលបន្ថែមទៀតតាមពីក្រោយដោយការលេចរូបរាងឡើងនៃ«ខ្លាអាស៊ី» និងការកើនឡើងសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង និងប្រទេសចិន។ ការផ្លាស់ប្តូរទាំងនេះ បង្ហាញពីការ ផលិតទាន់ពេលវេលា និងខ្សែចង្វាក់ផលិតកម្មរួម ដែលធ្វើឱ្យតំបន់អាស៊ី ប្រែក្លាយជាមជ្ឈមណ្ឌលកម្មន្តសាលពិភពលោក និងធ្វើឱ្យប្រទេសជាច្រើនអាចឡើងជណ្តើរប្រាក់ចំណូលបាន។ បច្ចុប្បន្ននេះ អាស៊ី និង ប៉ាស៊ីហ្វិក មានច្រើនជាងមួយភាគបីនៃផលដុលជាតិសរុបសកល ហើយត្រូវបានគេរំពឹងថានឹងចូលរួមចំណែកប្រហែល ២/៣ នៃកំណើនសកល ដែលនេះគូសបញ្ជាក់ពីការផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចសកលពហុប៉ូល។

**អាស៊ី និងប៉ាស៊ីហ្វិកបានត្រួសត្រាយអភិក្រមថ្មីក្នុងការអភិវឌ្ឍមនុស្ស។** អភិក្រមទាំងនេះ គឺរាប់ចាប់ពីការសង់លំនៅឋានសាធារណៈដ៏ធំទូលាយនៅក្នុងប្រទេសសិង្ហបុរី រហូតដល់មីក្រូហិរញ្ញវត្ថុប្រកបដោយនវានុវត្តន៍នៅក្នុងប្រទេសបង់ក្លាដែស និងការផ្តល់សេវាធនាគារចល័ត នៅក្នុងប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន ព្រមទាំងគំនិតទានទាគាំទ្រដល់ការអភិវឌ្ឍមនុស្សនៅក្នុងប្រទេសប៊ូតាន ស្រីលង្កា និងវៀតណាម។ ប្រទេសនានាអាចរៀនពីគ្នាទៅវិញទៅមក និងចេះកែសម្រួលគំនិតផ្សេងៗគ្នាឱ្យស្របតាមបរិបទជាក់លាក់ថ្មីៗរបស់ប្រទេសពួកគេ។ កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនេះបានជួយឱ្យប្រជាជនជាង ១.៥ ពាន់លាននាក់នៅក្នុងតំបន់ ចាកចេញពីភាពក្រីក្រខ្លាំង។

**តាមរយៈការកសាងដោយឈរលើអភិក្រមទាំងនេះ តំបន់នេះមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការអភិវឌ្ឍមនុស្សរយៈពេលវែង។** ក្នុងរយៈពេលបីទសវត្សរ៍ចុងក្រោយនេះ សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) ក្នុងតំបន់នេះបានកើនឡើង ១៩ ភាគរយ ដែលជាការលោតផ្លោះដ៏ធំបំផុតនៅលើពិភពលោក។

នៅប្រទេស**កម្ពុជា** HDI បានកើនឡើង៥៦.៩ភាគរយ តាំងពីឆ្នាំ១៩៩០ ដែលធ្វើឱ្យ**កម្ពុជា**ស្ថិតក្នុងក្រុមប្រទេសមានការអភិវឌ្ឍន៍មនុស្សមធ្យម ហើយមានចំណាត់ថ្នាក់ទី១៤៦ ក្នុងចំណោម១៩១ប្រទេសនៅឆ្នាំ២០២៣។ វឌ្ឍនភាពនេះក៏រួមបញ្ចូលការខាតបង់ដោយវិបត្តិកូវីដ១៩ផងដែរ។

**ប៉ុន្តែអត្ថប្រយោជន៍មិនត្រូវបានចែករំលែកស្មើៗគ្នានោះទេ។ វានៅតែមានភាពខុសគ្នាយ៉ាងទូលំទូលាយក្នុងចំណោមអនុតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងនៅទូទាំង និងក្នុងប្រទេសនានា ជាមួយនឹងអបរិយាប័ន្នជារចនាសម្ព័ន្ធដែលមានការរីករាលដាល និងរ៉ាំរ៉ៃ ។**

- *វិសមភាពនៅតែចាក់ឫសយ៉ាងជ្រៅ* - អ្នកមានជាងគេបំផុត ១០ ភាគរយ គ្រប់គ្រងយ៉ាងជាប់លាប់លើជាងពាក់កណ្តាល នៃប្រាក់ចំណូលសរុប ហើយជាពិសេសនៅអាស៊ីខាងត្បូង វិសមភាពប្រាក់ចំណូលមានសភាពកាន់តែអាក្រក់ទៅៗ។ ក៏មានវិសមភាពដ៏រ៉ាំរ៉ៃផងដែរ នៅក្នុងការបែងចែកទ្រព្យសម្បត្តិ ជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង ជាទីដែលមានវិសមភាពទ្រព្យសម្បត្តិខ្ពស់ជាងគេបំផុតដែលគេសង្កេតឃើញនៅក្នុងប្រទេសចិន ឥណ្ឌា មីយ៉ាន់ម៉ា ស្រីលង្កា និង ថៃ។ ជាមួយគ្នានេះ វឌ្ឍនភាពនៃការអភិវឌ្ឍមនុស្សជាទូទៅ មានលក្ខណៈមិនស្មើគ្នាខ្លាំងណាស់។ នៅ**កម្ពុជា** ចំពោះHDIដែលសម្របនឹងវិសមភាព វិញ (inequality-adjusted HDI) - ដោយផ្អែកលើធម្យមភាគវិសមភាពផ្នែកអប់រំ សុខភាព និងចំនូលរវាងបុរសនិងស្ត្រី - ពិន្ទុរបស់**កម្ពុជា**

គឺប្រហែលនឹងមធ្យមភាគពិភពលោក គឺខាតបង់HDI ប្រមាណ ១៩.២ភាគរយ ដោយសារវិសមភាព។

- *មនុស្សរាប់លាននាក់បានជាប់ក្នុងភាពក្រីក្រ* – ទោះបីជាមានការរីកចម្រើនយ៉ាងខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្ររូបិយវត្ថុ ដែលបានជំរុញមួយផ្នែកធំ ដោយសារការកើនឡើងសេដ្ឋកិច្ចរបស់ប្រទេសចិន យ៉ាងណាក៏ដោយ ក៏នៅមានប្រជាជនប្រហែល ១៨៥ លាននាក់ នៅតែក្រីក្រខ្លាំង នៅក្នុងលក្ខខណ្ឌដាច់ខាត ដោយទទួលបានប្រាក់ចំណូលតិចជាង ២.១៥ ដុល្លារក្នុងមួយថ្ងៃ។ ប្រជាជនជាច្រើនទៀតកំពុងរស់នៅក្បែរភាពក្រីក្រ ដោយមានប្រហែល ១ ពាន់លាន ត្រូវបានចាត់ថ្នាក់ថាជា "ក្រីក្រតាមសង្គម" ពោលគឺការរស់នៅដោយពឹងផ្អែកលើប្រាក់ចំណូលជាមធ្យមតិចជាងពាក់កណ្តាល។ វិធានការសំខាន់មួយទៀត គឺសន្ទស្សន៍ភាពក្រីក្រពហុវិមាត្រ (MPI) ដែលគិតគូរពីភាពខ្វះខាតក្នុង វិស័យអប់រំ សុខាភិបាល និងកម្រិតជីវភាពរស់នៅ។ អាស៊ី និងប៉ាស៊ីហ្វិក មានប្រជាជនដែលមានការខ្វះខាតខ្លាំង ប្រហែលពាក់កណ្តាលនៃប្រជាជនខ្វះខាតខ្លាំងនៅលើពិភពលោក – ៥០០លាននាក់។ ក្នុងចំណោមប្រជាជនទាំងនេះ ៤០០លាននាក់ នៅអាស៊ីខាងត្បូង បើទោះបីជាប្រទេសឥណ្ឌា អាចធ្វើឱ្យប្រជាជន ៤១៥ លាននាក់ចាកចេញពីភាពក្រីក្រច្រើនសូចនាករ ចាប់តាំងពីឆ្នាំ២០០៥ យ៉ាងណាក៏ដោយ។ នៅ **កម្ពុជា** អត្រានៃភាពក្រីក្រពហុសមាសភាគ (multidimensional poverty) បានធ្លាក់ចុះពី៣៦.៧ភាគរយក្នុងឆ្នាំ២០១៤ មកត្រឹម១៦.៦ភាគរយក្នុងឆ្នាំ២០២៣។ នេះមានន័យថាចំនួនប្រជាពលរដ្ឋក្រីក្រកាត់បន្ថយពាក់កណ្តាលពី៥.៦លាននាក់មកត្រឹម២.៨លាននាក់ក្នុងរយៈពេលត្រឹមតែ៧ឆ្នាំកន្លះប៉ុណ្ណោះ។ វឌ្ឍនភាពរបស់**កម្ពុជា**មួយផ្នែកធំ សម្រេចបានតាមរយៈភាពប្រសើរឡើងផ្នែកសុខភាព និងជីវភាព ជាពិសេសអត្រាមរណភាពកុមារ អាហារូបត្ថម្ភ ការប្រើប្រាស់ឥន្ធនៈចំអិន អនាម័យ និងអគ្គិសនី។ ប៉ុន្តែបញ្ហាប្រឈមនៅតែមានសម្រាប់សូចនាករអប់រំ និងលំនៅឋាន ដោយភាពងាយរងគ្រោះនៅតែខ្ពស់។

- *អាស៊ី និងប៉ាស៊ីហ្វិក មានភាពលំអៀងយេនឌ័រខ្លាំង* – ឧ. ស្ត្រីបានទទួលផលក្នុងវិស័យអប់រំ និងសុខភាព និងលទ្ធភាពទទួលបានហិរញ្ញវត្ថុ ដូចជានៅអាស៊ីខាងត្បូង ដែលភាពជាម្ចាស់នៃគណនីហិរញ្ញវត្ថុ បានកើនឡើងពី ២៤ ដល់ ៦៦ ភាគរយ ក្នុងរយៈពេលមួយទសវត្សរ៍។ ទោះបីជាយ៉ាងណាក៏ដោយ ស្ត្រីនៅតែមានការរារាំងដោយភាពលំអៀង និងរបាំងជារចនាសម្ព័ន្ធជាច្រើន ហើយនៅក្នុងប្រទេសមួយចំនួន ស្ត្រីបានទទួលរងនូវការធ្លាក់ចុះយ៉ាងខ្លាំងនៃសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាច ដែលឧបសគ្គជាក់លាក់របស់ស្ត្រីធ្វើការនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន គឺជាក្តីព្រួយបារម្ភយ៉ាងខ្លាំងមួយ។ នៅទូទាំងតំបន់ ស្ត្រីប្រហែល ៨០០លាននាក់ ស្ថិតនៅក្រៅកម្លាំងពលកម្ម។ ឧទាហរណ៍ នៅ សាធារណរដ្ឋឥស្លាមអ៊ីរ៉ង់ ការចូលរួមកម្លាំងពលកម្មរបស់ស្ត្រីមាន ១៤ ភាគរយ ទោះបីជាមានការចុះឈ្មោះចូលរៀនខ្ពស់ ក្នុងការអប់រំយ៉ាងណាក៏ដោយ ហើយនៅប្រទេសប៉ាគីស្ថាន មាន ២៥ ភាគរយ ធៀបនឹង ៦៩ ភាគរយ នៅវៀតណាម។ **កម្ពុជា**ក៏មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការលើកកម្ពស់សមភាពយែនឌ័រ – ដោយផ្អែកលើភាគរយស្ត្រីក្នុងសភា ការអប់រំ កម្លាំងពលកម្ម ក៏ដូចជាអត្រាមរណភាពមាតា – ដោយគម្លាតយែនឌ័របានធ្លាក់ចុះពី ០.៦៧៩ ក្នុងឆ្នាំ១៩៩០ មកត្រឹម ០.៤៦១ នៅឆ្នាំ២០២៣ (ដោយ ១ មានន័យថាគម្លាតខ្ពស់បំផុង និង ០ គ្មានគម្លាតយែនឌ័រ)។ នេះធ្វើឱ្យ**កម្ពុជា** ស្ថិតក្នុងចំណាត់ថ្នាក់១១៦ក្នុងចំណោម១៧០ប្រទេសសម្រាប់សន្ទស្សន៍វិសមភាពយែនឌ័រនៅឆ្នាំ២០២៣។

- *កម្មកររាប់លាននាក់ត្រូវបានបង្ខាំងនៅក្នុងវិស័យក្រៅផ្លូវការ ហើយមានគម្លាតផ្នែកឌីជីថលយ៉ាងខ្លាំង* – អាស៊ី និងប៉ាស៊ីហ្វិក មានកម្មករក្នុងវិស័យក្រៅផ្លូវការប្រហែល ២/៣ របស់ពិភពលោក ដែលមានចំនួនប្រហែលជា ១.៣ ពាន់លាននាក់។ នៅអាស៊ីខាងត្បូង សមាមាត្រនៃកម្មករក្នុងវិស័យក្រៅផ្លូវការ មាន ៨៧ ភាគរយ ហើយសូម្បីតែនៅអាស៊ីបូព៌ាក៏មាន ៥០ ភាគរយ ដែរ។ នៅកម្រិតប្រទេសវិញ នៅឯចុងម្ខាងនៃវិសាលគមនេះ គឺប្រទេសតុងហ្គា មាន ៩៧ ភាគរយ និងនៅឯចុងម្ខាងទៀតគឺសាធារណរដ្ឋកូរ៉េ មាន ២៧ ភាគរយ។ នៅ**កម្ពុជា** ប្រជាពលរដ្ឋប្រមាណ៨៨ភាគរយកំពុងបម្រើការក្នុងវិស័យក្រៅប្រព័ន្ធនៅឆ្នាំ២០១៩។

- លើសពីនេះ ក៏មានភាពខុសគ្នាយ៉ាងធំធេងផងដែរ ចំពោះការប្រើប្រាស់ឌីជីថល៖ ៤០ ភាគរយនៃប្រជាជនក្នុងតំបន់គឺអបរិយាប័ន្នឌីជីថល ជាមួយនឹងវិសមភាពនៃយេនឌ័រ និងការរស់នៅក្នុងតំបន់ទីក្រុង-ជនបទ គួរឱ្យកត់សម្គាល់។ នៅ**កម្ពុជា** ការប្រើប្រាស់អ៊ីនធឺណែត និងទូរស័ព្ទចល័តគឺមានភាគច្រើននៅតំបន់ប្រជុំជន។ ដោយផ្អែកលើរបាយការណ៍ភាពប្រកួតប្រជែងសកលឆ្នាំ២០១៩ដោយវេទិកាសេដ្ឋកិច្ចពិភពលោក **កម្ពុជា**ឈរចំណាត់ថ្នាក់១០២ក្នុងចំណោម ១៤១ប្រទេសសម្រាប់ដំណភ្ជាប់ និងភាពរួចរាល់ផ្នែកឌីជីថល។ នៅឆ្នាំ២០២២ រាជរដ្ឋាភិបាល**កម្ពុជា**ប៉ាន់ប្រមាណ មានប្រជាពលរដ្ឋ**កម្ពុជា**ប្រមាណ៣០ភាគរយប៉ុណ្ណោះ ដែលមានជំនាញឌីជីថលបឋមក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការស្រាវជ្រាវតាមអ៊ីនធឺណែត ទំនាក់ទំនង និងចែករំលែកព័ត៌មាន។

- *ក៏មានគម្លាតដ៏ធំនៃ "សម្ពាធភពផែនដី" ផងដែរ*។ អាស៊ី និងប៉ាស៊ីហ្វិក មានប្រទេសនៅទូទាំងវិសាលគមឧស្ម័នផ្ទះកញ្ចក់ទាំងមូល ដោយមានការបញ្ចេញឧស្ម័នច្រើន និងតិច ហើយប្រទេសវិជ្ជមានសុទ្ធចំពោះការបញ្ចេញឧស្ម័ន ដូចជាប្រទេសប៊ូតង់ និងប្រទេសមួយចំនួនទៀត គឺប្រឈមមុខបំផុតទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ឥន្ធនៈហ្វូស៊ីលមានចំនួន ៨៥ ភាគរយនៃការប្រើប្រាស់ថាមពល ហើយក្នុង រយៈពេលជាងបីទសវត្សរ៍កន្លងមកនេះ ការរួមចំណែករបស់អាស៊ីប៉ាស៊ីហ្វិកចំពោះការបំភាយឧស្ម័ន $CO_2$ សកលបានកើនឡើងពីមួយភាគបួនដល់ពាក់កណ្តាល។ ជីវចម្រុះរបស់ ភពផែនដីកំពុងស្ថិតក្រោមការគំរាមកំហែង ដោយសារការបាត់បង់ទីជម្រក ការបំពុល ការកេងប្រវ័ញ្ចហួសប្រមាណ និងប្រភេទសត្វដែលឈ្លានពាន ហើយវាកំពុងធ្លាក់ក្នុងស្ថានភាពកាន់តែធ្ងន់ធ្ងរ ដោយសារការប្រែប្រួលអាកាសធាតុ។ ចាប់តាំងពីឆ្នាំ១៩៧០ តំបន់អាស៊ី-ប៉ាស៊ីហ្វិក ត្រូវបានគេមើលឃើញថាមានការធ្លាក់ចុះជីវចម្រុះច្រើនបំផុតទីបីនៅលើពិភពលោក បន្ទាប់ពីតំបន់អាមេរិកឡាទីន និងអាហ្វ្រិក។ សម្ពាធផ្នែកអេកូឡូស៊ី និងបរិស្ថានបែបនេះ បានបង្កើនហានិភ័យដល់ប្រជាជន ២០០ លាននាក់នៅក្នុងតំបន់ ដែលពឹងផ្អែកលើព្រៃឈើសម្រាប់

សុខភាព និងជីវភាពរស់នៅរបស់ពួកគេ។ នៅពេលគិតគូរពីកត្តាធ្លាក់ចុះបរិស្ថានទាំងនេះ រូបភាពនៃការអភិវឌ្ឍមនុស្សកាន់តែងងឹតជាពិសេសសម្រាប់ប្រទេសអ្នកមាន ដែលមានការបំភាយឧស្ម័នកាបូនិចខ្លាំង។ ស្របពេលជាមួយគ្នានេះ ដោយផ្អែកលើ HDIដែលសម្របនឹងសម្ពាធលើភពផែនដី (planetary pressure-adjusted HDI) ការបំភាយឧស្ម័នកាបូននិងប្រើប្រាស់ធនធានរ៉ែក្នុងម្នាក់ៗសម្រាប់**កម្ពុជា** ធ្វើឱ្យHDI ធ្លាក់ចុះ ៣.៤ភាគរយ ដែលអាចប៉ះពាល់ប្រជាពលរដ្ឋក្រីក្រនិងងាយរងគ្រោះ។

*ចំពោះការប្រែប្រួលអាកាសធាតុវិញ ចេតនាល្អៗកម្រនឹងមានសកម្មភាពអនុវត្តជាក់ស្តែងណាស់ ហើយការបំភាយឧស្ម័នកាបូនិច នៅតែបន្តកើនឡើង* - គិតត្រឹមខែសីហា ឆ្នាំ ២០២២ ប្រទេសចំនួន ៣០ បានសន្យាអព្យាក្រឹតភាពកាបូន ប៉ុន្តែប្រទេសភាគច្រើន នៅខ្វះការបង្កើតយុទ្ធសាស្ត្រល្អៗក្នុងការផ្តល់ហិរញ្ញប្បទាន ដើម្បីធ្វើឱ្យការសន្យានេះមានប្រសិទ្ធភាពនៅឡើយទេ។ ឧទាហរណ៍ ក្នុងឆ្នាំ២០២២ ប្រទេសឥណ្ឌូនេស៊ី បានបង្កើនការដុតធ្យូងថ្ម ៣៣ ភាគរយធៀបនឹងឆ្នាំមុន។ ជារឿយៗ រដ្ឋាភិបាលជាច្រើន បានផ្តល់អាទិភាពកាន់តែខ្លាំងទៅលើកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ឬបានប្រើប្រាស់ការនាំចេញធ្យូងថ្មដើម្បីទូទាត់បំណុលខាងក្រៅដែលកំពុងកើនឡើង។ ទោះបី**កម្ពុជា** មានការបំភាយឧស្ម័នផ្ទះកញ្ចក់ក្នុងកម្រិតទាប ការបំភាយឧស្ម័នកំពុងមានការកើនឡើងស្របពេលមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ប្រមាណ៤៩ភាគរយនៃការបំភាយឧស្ម័នពុលគឺតាមរយៈការប្រើប្រាស់ក្នុងវិស័យព្រៃឈើនិងដីធ្លី តាមពីក្រោយដោយ ថាមពល (២២%) កសិកម្ម(១៨%) ឧស្សាហកម្ម(៩%) និងកាកសំណល់(២%)។

**រួមជាមួយនឹងពិភពលោកទាំងមូល អាស៊ី និងប៉ាស៊ីហ្វិក បានជួបប្រទះបញ្ហារំខានយ៉ាងអន្តរាយជាបន្តបន្ទាប់ ជាពិសេសជំងឺរាតត្បាតកូវីដ-១៩ ផលប៉ះពាល់នៃសង្គ្រាមនៅអ៊ុយក្រែន និងវិបត្តិនៃការចំណាយលើការរស់នៅ។**

- *ជំងឺរាតត្បាត និងការបិទខ្ទប់ជាបន្តបន្ទាប់ បានប៉ះពាល់ កម្លាំងការងារក្រៅផ្លូវការក្នុងតំបន់ប្រហែលពាក់កណ្តាល* - មានប្រទេសជាច្រើន បានទទួលរងការខាតបង់ប្រាក់ចំណូលយ៉ាងធ្ងន់ធ្ងរ ពីទេសចរណ៍ ការផ្ញើរប្រាក់ និងកម្មន្តសាលកម្ម ដែលផ្តល់ការងារដល់កម្មករក្រៅផ្លូវការមួយចំនួនធំ ជាពិសេសតាមបណ្តាប្រទេសកោះនៅប៉ាស៊ីហ្វិក។ ជាក់ស្តែង ក្នុងតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ហេតុការណ៍តក់ស្លុតទាំងនេះ បានបង្ហាញឱ្យឃើញពីភាពទន់ខ្សោយនៃប្រព័ន្ធថែទាំសុខភាព។ ក្រោយមកទៀត ក៏កើតមានសង្គ្រាមនៅអ៊ុយក្រែន និងវិបត្តិនៃការចំណាយលើការរស់នៅជាបន្តបន្ទាប់។ នៅឆ្នាំ២០២០ និង ២០២១ រួមជាមួយនឹងជំងឺរាតត្បាត គ្រោះកាចជាបន្តបន្ទាប់នេះបាននាំឱ្យមានការធ្លាក់ចុះយ៉ាងទូលំទូលាយនៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៅក្នុងអនុតំបន់ទាំងអស់ លើកលែងតែអាស៊ីបូព៌ាមួយប៉ុណ្ណោះ។ បណ្តាប្រទេសដែលមានវិបត្តិ ម៉ាក្រូសេដ្ឋកិច្ច និងបំណុល បានរងគ្រោះខ្លាំងជាងគេ។ នៅ**កម្ពុជា** វិបត្តិកូវីដ១៩បានធ្វើឱ្យប្រទេសនេះខាតបង់ការអភិវឌ្ឍន៍មនុស្សដែលខំកសាងមកយ៉ាងលំបាក ដោយក្នុងនោះសន្ទស្សន៍HDIបានរំកិលថយក្រោយប្រហែលនឹងកម្រិតនៅឆ្នាំ២០១៨។ តាមរយៈ[ការសិក្សារបស់UNDPនៅឆ្នាំ២០២៣](#) នៅ**កម្ពុជា** សង្គ្រាមនៅអ៊ុយក្រែនបានធ្វើឱ្យមានការកើនឡើងតម្លៃទំនិញ ដែលធ្វើឱ្យប៉ះពាល់ដល់ផលដុលជាតិសរុប(GDP) ប្រមាណ ១.៣ ទៅ ១.៥ ភាគរយ ហើយអាចធ្វើឱ្យអត្រាភាពក្រីក្រកើងឡើងក្នុងរង្វង់០.៧ភាគរយបន្ថែមទៀតនៅឆ្នាំ២០២២។ ទោះបីជាយ៉ាងណា ជារួម **កម្ពុជា**នៅតែអាចរក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ គឺ៥.២ភាគរយនៅឆ្នាំ២០២២ និង៥.៣ ភាគរយនៅឆ្នាំ២០២៣។

- *រងគ្រោះខ្លាំងបំផុតគឺស្ត្រីនៅក្នុងគ្រួសារក្រីក្រ* - នាពេលថ្មីៗនេះ តំបន់នេះ ត្រូវបានគេឃើញថាមានការធ្លាក់ចុះ សមភាពយេនឌ័រដ៏អាក្រក់បំផុតរបស់ខ្លួន នៅក្នុងរយៈពេលពីរទសវត្សរ៍ ជាពិសេសនៅតំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក។ ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺរាតត្បាត ស្ត្រីបានទទួលរងបន្ទុកមិនសមាមាត្រនៃកាតព្វកិច្ចក្នុងផ្ទះ រួមមានការងារផ្ទះ និងការថែទាំកុមារ និងសមាជិកគ្រួសារឈឺ និងចាស់ជរា។ ក្នុងអំឡុងឆ្នាំ ២០២០ និង ២០២១ មានផលវិបាកយ៉ាងធ្ងន់ធ្ងរនៅក្នុងប្រទេស ប្រទេសប៉ាពួញូហ្គីណេ និងមីយ៉ាន់ម៉ា ហើយជាពិសេសនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន ជាកន្លែងដែលស្ត្រីបានជួបប្រទះនូវវឌ្ឍនៈភាពជាច្រើនទសវត្សរ៍ តែប្រែជា អវិជ្ជមាន ជាមួយនឹងការរំលោភសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ពួកគេយ៉ាងធ្ងន់ធ្ងរ។ តាមរយៈ[ការសិក្សារបស់UNDPនៅឆ្នាំ២០២១](#) នៅ**កម្ពុជា** វិបត្តិកូវីដ១៩ បានប៉ះពាល់ដល់វិស័យវាយនភ័ណ្ឌនិងទេសចរណ៍ដែលមានកម្លាំងពលកម្មស្ត្រីច្រើនជាងគេ ដែលក្នុងនោះអត្រានៃភាពអត់ការងារធ្វើរបស់ស្ត្រីរំពឹងថា អាចឡើងដល់៣.២ ភាគរយ បើធៀបនឹងបុរសត្រឹម ២.៦ភាគរយ ដែលជាគម្លាតយេនឌ័រផ្នែកការងារប្រមាណ០.៦ភាគរយ។

- *ជាចុងក្រោយ ក្នុងរយៈពេលមួយទស្សវត្សរ៍កន្លងមកនេះ តំបន់នេះបានឃើញនូវការដើរបញ្ច្រាស់នៃការអនុវត្តលទ្ធិប្រជាធិបតេយ្យ*-ការរីករាលដាលនៃជំងឺរាតត្បាត ធ្វើឱ្យរដ្ឋាភិបាលរឹតបន្តឹងលើសេរីភាពពលរដ្ឋ និងរំលោភសិទ្ធិនយោបាយ ស្របពេលជាមួយគ្នានេះក៏បានធ្វើឱ្យយន្តការគណនេយ្យភាពចុះខ្សោយ ផងដែរ។ អាស៊ីនិងប៉ាស៊ីហ្វិក បានឃើញនូវការប្រែប្រួលនាពេលថ្មីៗនេះឆ្ពោះទៅរកការកំណត់លំហរសាធារណៈ និងពលរដ្ឋ ក្នុងកម្រិតមួយដែលបានកើតឡើងចុះក្រោយនៅចុងទសវត្សរ៍ឆ្នាំ១៩៧០ ហើយហាក់ដូចជាមានក្តីសង្ឃឹមតិចតួចប៉ុណ្ណោះនៃការងើបឡើងវិញភ្លាមៗនៃលទ្ធិប្រជាធិបតេយ្យ។ ចំណុចនេះមានផលប៉ះពាល់យ៉ាងខ្លាំង នៅក្នុងទីតាំងមួយចំនួន សម្រាប់គន្លងនៃការអភិវឌ្ឍជារួម ក៏ដូចជាសម្រាប់បរិយាប័ន្ន និងសមភាព។ ហើយប្រសិនបើការផ្លាស់ប្តូរ ខាងលើនាំឱ្យមានការផ្តាច់មុខដែរនោះ វានឹងកាត់បន្ថយការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចជាមិនខាន។

## បំណងប្រាថ្នាមិនបានសម្រេច អសន្តិសុខមនុស្សកើនឡើង និងអនាគតកាន់តែរីករវរ បង្កើតតម្រូវការបន្ទាន់ឱ្យមានការផ្លាស់ប្តូរ

**តាមនិន្នាការបច្ចុប្បន្ន តំបន់នេះមិនស្ថិតនៅលើមាគ៌ាដែលផ្តល់នូវការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបចីរភាព (SDGs) ណាមួយឡើយ**។ គម្លាតដ៏ធំមួយ បានបើកចំហរ រវាងបំណងប្រាថ្នា និងការពិត ជាមួយនឹង

ដំណើរថយក្រោយគួរឱ្យបារម្ភ សម្រាប់គោលដៅប្រែប្រួលអាកាសធាតុ។ ឥឡូវនេះ គេរំពឹងថា SDGs នឹងមិនបានសម្រេចនៅត្រឹមឆ្នាំ ២០៣០ ឡើយ ប៉ុន្តែបានសម្រេចនៅត្រឹមឆ្នាំ ២០៦៥។ ទោះបីជាយ៉ាងណាក៏ដោយ ខ្លឹមសារ និងមហិច្ឆតានៃរបៀបវារៈឆ្នាំ ២០៣០ នៅតែមានភាពពាក់ព័ន្ធដូចពីមុនដដែល។

**នៅទូទាំងអាស៊ី និងប៉ាស៊ីហ្វិក មនុស្សរាប់លាននាក់រស់នៅក្នុងជីវិតមិនច្បាស់លាស់ជាមួយនឹងការគំរាមកំហែងជាច្រើនដល់សន្តិសុខរបស់ពួកគេ ទាំងផ្នែកសង្គម នយោបាយ និងបរិស្ថាន**។ ជាពិសេសនៅអាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង បណ្តាប្រទេសនានាកំពុងប្រឈមនឹងជម្លោះ ភាពចលាចលនយោបាយ ឬឧបសគ្គសេដ្ឋកិច្ចធំៗ។ បំណងប្រាថ្នាដែលមិនបានសម្រេច ចំពេលអសន្តិសុខមនុស្សកើនដល់កម្រិតខ្ពស់ បង្កើតឱ្យមានការរួមផ្សំគ្នាមួយ ដែលមានលក្ខណៈងាយនឹងប្រែប្រួល និងអាចឆាបឆេះយ៉ាងងាយស្រួល ជាហេតុធ្វើឱ្យកាន់តែពិបាកក្នុងការសម្រេចបាននូវការអភិវឌ្ឍមនុស្សឱ្យបានជាប់លាប់។

**តំបន់នេះក៏ប្រឈមមុខផងដែរនឹងអនាគតដែលនឹងអាចកាន់តែរីករវស្របពេលដែលទិដ្ឋភាពនៃការអភិវឌ្ឍ កំពុងត្រូវបានកែទម្រង់ដោយសារចង្កោមនៃហានិភ័យមានភាពប្រទាក់ក្រឡាចំនួនបី។**

- *ហានិភ័យដែលកំពុងកើតមានស្រាប់* - មួយក្នុងចំណោមការគម្រាមកំហែងដែលកំពុងកើតមានស្រាប់ដ៏ធ្ងន់ធ្ងរបំផុត គឺការប្រែប្រួលអាកាសធាតុ។ លើសពីនេះ មានការរំពឹងថានឹងមានជំងឺរាតត្បាតនាពេលអនាគតស្រដៀងគ្នា នឹងជំងឺកូវីដ-១៩ ដែរ ជាមួយនឹងលទ្ធភាពកើតឡើងវិញប្រហែល ៥០ ភាគរយ ក្នុងរយៈពេល ២៥ ឆ្នាំខាងមុខនេះ។ ហានិភ័យទាំងនេះ មានការកើនឡើង តាមរយៈ វិធីសាស្ត្រដែលមនុស្សមានអន្តរកម្មជាមួយធម្មជាតិ។ ទីក្រុងបន្តរីកចម្រើនយ៉ាងឆាប់រហ័ស ដោយសារកំណើនចំនួនប្រជាជន ការធ្វើចំណាកស្រុក និងការទាក់ទាញខាងសេដ្ឋកិច្ច ហើយនាពេលបច្ចុប្បន្ននេះ តំបន់នេះ គឺជាទីកន្លែងដែលមានទីក្រុងធំជាងគេបំផុត ចំនួនប្រាំមួយ របស់ពិភពលោកដូចជាទីក្រុងតូក្យូ និងទីក្រុងបុមបៃជាដើម។

- *បញ្ហាប្រឈមនានាចំពោះការបង្កើតកំណើន និងម៉ាស៊ីនបង្កើតការងារ* - ស្របពេលដែលប្រទេសអ្នកមាន កំពុងដោះស្រាយបញ្ហាប្រជាជនកាន់តែមានវ័យចំណាស់ ដែលធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធសុខាភិបាល និងសង្គមរបស់ពួកគេ ប្រទេសមិនសូវមានធនធានព្យាយាមផ្តល់ការងារ និងសេវាសំខាន់ៗ ដល់យុវជនរបស់ពួកគេ។ នៅអាស៊ីខាងត្បូង ៨០ ភាគរយនៃកម្មករវ័យក្មេងស្ថិតនៅក្នុងវិស័យក្រៅផ្លូវការ ហើយ ៣០ ភាគរយមិននៅក្នុងវិស័យអប់រំ និងការងារ។ ភាពអត់ការងារធ្វើរបស់យុវជននៅតែបន្តកើតមាន ហើយនៅក្នុងប្រទេសមួយចំនួន មានការកើនឡើងថែមទៀតផង។ ទន្ទឹមនឹងនេះ សកលភាវូបនីយកម្មបាននិងកំពុងតែចុះខ្សោយ ដោយសារភាពតានតឹងផ្នែកភូមិ សាស្ត្រនយោបាយ ការងើបឡើងវិញយឺតនៃសេដ្ឋកិច្ចប្រទេសអ្នកមាន និងវិសមភាពដែលកំពុងកើនឡើង។ ភាពជឿនលឿនផ្នែកបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស និងអន្តរកាលថាមពលបានបង្កើតឱកាសថ្មីៗ ប៉ុន្តែក៏បង្កើតបញ្ហាប្រឈមសម្រាប់ទីផ្សារការងារ និងការប្រកួតប្រជែង ផងដែរ។

- *ហានិភ័យចំពោះសន្ទុះនៃការផ្លាស់ប្តូរ* - នៅក្នុងយុគសម័យមួយដែលត្រូវបានកំណត់ដោយបំណងប្រាថ្នាមិនបានសម្រេច និងភាពមិនប្រាកដប្រជា នោះសក្តានុពលសម្រាប់ការធ្វើកំណែទម្រង់ ក៏នឹងកំពុងធ្លាក់ចុះផងដែរ ដោយសារកត្តាមួយចំនួន ដូចជា ការធ្លាក់ចុះនៃលទ្ធិប្រជា ធិបតេយ្យ ការកើនឡើងប្រជានិយម ការបែងខ្ញែកពហុប៉ូល និងការរីកលូតលាស់នៃព័ត៌មានមិនពិត នៅលើវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមនានា។ លើសពីនេះ ស្របពេលបច្ចេកវិទ្យាឌីជីថលនាំមកនូវអត្ថប្រយោជន៍ជាច្រើន វាក៏អាចមានលទ្ធផលអវិជ្ជមាន ផងដែរ។ ឧទាហរណ៍ នៅពេលដែលការបន្តឱ្យប្រើប្រាស់ដោយបើកចំហ គឺជាគន្លឹះ នោះវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម ដឹកនាំដោយ AI បានចូលមកដើរតួយ៉ាងទូលំទូលាយក្នុងការតម្រង់ទិសសាធារណៈមតិ និងជំរុញឱ្យមានការបែកបាក់។ ចំពេលមានលំហរនៃគំនិតបែកខ្ញែកគ្នាដ៏ខ្មៀវខ្មារ វាកាន់តែពិបាកក្នុងការបង្កើត និងអនុវត្តការផ្លាស់ប្តូរដែលគិតទៅមុខ។

**ចង្កោមទាំងនេះ និងសមាសធាតុរបស់ពួកវាមានលក្ខណៈត្រួតគ្នាដោយជៀសមិនរួច**។ ឧទាហរណ៍ នគរូបនីយកម្ម ខណៈដែលវាជួយសម្រួលដល់ការរីករាលដាលនៃមេរោគ វាក៏បានជួយជំរុញកំណើនសេដ្ឋកិច្ច ផងដែរ តាមរយៈការនាំមនុស្ស និងធុរកិច្ចឱ្យជួបគ្នា។ ការប្រើប្រាស់ AI និងប្រព័ន្ធផ្សព្វផ្សាយសង្គម ប្រសិនបើមិនបានកំណត់ដោយអាកប្បកិរិយាវិជ្ជមាន និងដោយសកម្មភាពបទប្បញ្ញត្តិច្បាប់ទេ ប្រហែលជាមិនត្រឹមតែលុបបំបាត់ការងារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរារាំងដល់ការអនុវត្តគោលនយោបាយទៀតផង តាមរយៈការបង្កើនជម្លោះ និងការចូលរួមចំណែកដល់ព័ត៌មានមិនពិត។ សកម្មភាពគោលនយោបាយក៏អាចកាត់ផ្តាច់ចង្កោមទាំងនេះផងដែរ ដូចជានៅពេលដាក់ពង្រាយការផលិតថាមពលពន្លឺព្រះអាទិត្យដើម្បីទប់ទល់នឹងហានិភ័យដែលកំពុងកើតមាន វាក៏អាចជំរុញសសរស្តម្ភថ្មីៗនៃកំណើន ។

## ការកំណត់ទិសដៅថ្មីៗសម្រាប់ការអភិវឌ្ឍមនុស្សនឹងតម្រូវឱ្យមានការកែប្រែឡើងវិញនូវការអនុវត្តចាស់ៗ ប៉ុន្តែតំបន់នេះអាចស្វែងរកការបំផុសគំនិតនៅក្នុងគំរូផ្ទាល់របស់ខ្លួន។

**កំណើនដឹកនាំដោយការនាំចេញ និងលំនាំអភិវឌ្ឍន៍មនុស្ស ដែលមានដើមកំណើតនៅក្នុងតំបន់ នៅតែជាប្រភពដ៏សម្បូរបែបនៃគំនិត និងការបំផុសគំនិត ប៉ុន្តែវាទាមទារឱ្យមានការសម្របខ្លួន ដើម្បីរក្សាប្រសិទ្ធភាពរបស់វា**។ តំបន់អាស៊ី-ប៉ាស៊ីហ្វិក គឺជាកន្លែង កំណើតនៃយុទ្ធសាស្ត្រកំណើនដឹកនាំដោយការនាំចេញ ហើយជាកន្លែងដែលអភិក្រមអភិវឌ្ឍន៍មនុស្ស ដែលជាគំនិតផ្តួចផ្តើមរបស់អ្នកសេដ្ឋកិច្ចវិទូអាស៊ីខាងត្បូងពីររូប មានដំណើរការនៅទូទាំងប្រទេសមួយចំនួន។

ទោះជាយ៉ាងនេះក្តី ដើម្បីធានានូវលទ្ធផលកាន់តែរីកចម្រើន កាន់តែមានសមធម៌ និងមានចីរភាពបរិស្ថាន នៅក្នុងសតវត្សទី២១ នេះ លំនាំទាំងនេះចាំបាច់ត្រូវកែទម្រង់ ធ្វើទំនើបកម្ម និងបញ្ជ្រាបការយល់ដឹង។ ជាពិសេសអភិក្រមអភិវឌ្ឍន៍មនុស្ស គួរត្រូវបានប្រតិបត្តិឱ្យ កាន់តែទូលំទូលាយ ប្រសិនបើវាគឺដើម្បីបំពេញសិទ្ធិ និងបំពេញតម្រូវការរបស់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគត។ ហើយគំរូកំណើនដឹកនាំដោយការនាំចេញ ត្រូវតែ

វិវឌ្ឍទៅតាមពេលវេលា ប្រសិនបើវាគឺដើម្បីបង្កើតប្រភេទកំណើនត្រឹមត្រូវ ដែលបង្កើតការងារច្រើន និងពង្រឹងការអភិវឌ្ឍមនុស្ស នៅគ្រប់ទិដ្ឋភាពទាំងអស់របស់វា។

**ប៉ុន្តែ "ការបង្កើតអនាគតរបស់យើង" យ៉ាងពិតប្រាកដ គឺមានន័យថាជាការឈានទៅមុខមួយជំហានទៀត និងការដោះស្រាយបញ្ហាអភិបាលកិច្ច និងនយោបាយកំណែទម្រង់។** ការប្រែក្លាយគំនិតទៅជាសកម្មភាព នឹងតម្រូវឱ្យមានភាពជាអ្នកដឹកនាំកាន់តែពោរពេញដោយបរិសកម្ម និងចក្ខុវិស័យ។ ជាមួយនឹងការបង្កើតគោលនយោបាយដែលមានលក្ខណៈគិតទុកជាមុន បន្សាំ និងរហ័សរហួន នោះអភិបាលកិច្ចដែលមានលក្ខណៈបរិសកម្ម អាចបែងចែកឡើងវិញនូវធនធាន និងអាទិភាពឆ្ពោះទៅរកគោលនយោបាយ និងកម្មវិធីថ្មីៗ បានយ៉ាងឆាប់រហ័ស។ វាក៏អាចគាំទ្រផងដែរដល់ការអភិវឌ្ឍផ្តោតលើចក្ខុវិស័យ ស្របពេលកំពុងបង្កើតមតិឯកភាពជារួម កិច្ចសហការ និងភាពជាដៃគូ ព្រមទាំងជួយសម្រួលដល់ការ វិនិយោគក្នុងវិស័យសំខាន់ៗ និងសមត្ថភាពមនុស្ស។ ជាមូលដ្ឋានជាងនេះទៅទៀត វាក៏មានសារៈសំខាន់ផងដែរក្នុងការលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរខ្លួនឯង។ វានឹងតម្រូវឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅ និងផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើរបាំងផ្លូវសង្គម-នយោបាយ និងវិធីបង្កើតមធ្យោបាយជុំវិញវា។

## តាមរយៈការផ្តល់អាទិភាពដល់តម្រូវការរបស់មនុស្ស ទាំងនៅពេលបច្ចុប្បន្ន និងនាពេលអនាគត ប្រទេសនានាអាចពង្រីកឱកាសសម្រាប់ទាំងអស់គ្នា កាត់បន្ថយអសន្តិសុខមនុស្ស និងប្រកាន់ខ្ជាប់កាតព្វកិច្ចទៅដល់មនុស្សជំនាន់ក្រោយ។

**ការអនុវត្តលើការអភិវឌ្ឍមនុស្ស អាចនឹងត្រូវដាក់បញ្ចូលយ៉ាងជិតស្និទ្ធទៅក្នុងសង្វៀននៃការសម្រេចចិត្តស្នូលរបស់តំបន់។** ទស្សនៈដែលផ្តោតលើប្រជាជន និងសំឡេងរបស់មនុស្សជំនាន់ក្រោយ ជារឿយៗត្រូវបានបដិសេធ ខណៈដែលបញ្ហាវិនាសនាពេលថ្មីៗនេះបានបង្ហាញខ្លួន ហើយវិសមភាពដ៏រ៉ាំរ៉ៃ នៅតែបន្តកើតមាន។

វាជារឿងសំខាន់ដែលអតុល្យភាពនេះត្រូវបានកែតម្រូវ ខណៈដែលយើងរំពឹងទុកថា ការផ្លាស់ប្តូរនាពេលខាងមុខនឹងកែប្រែទិដ្ឋភាពនៃការអភិវឌ្ឍរបស់យើង។ ចំពោះបញ្ហានេះ អាចមានអាទិភាពធំៗបី។

**ទីមួយ - ពង្រីកជម្រើសរបស់មនុស្ស**

- *ដោះស្រាយបញ្ហាអបរិយាប័ន្នជារចនាសម្ព័ន្ធដ៏រ៉ាំរ៉ៃ និងប្រកាន់ខ្ជាប់សេចក្តីថ្លៃថ្នូររបស់មនុស្ស*។ ឧទាហរណ៍ វាអនុវត្តចំពោះស្ត្រី យុវជន កម្មករក្រៅផ្លូវការ ជនមានពិការភាព មនុស្សស្រលាញ់ភេទដូចគ្នា (LGBTQI+) និងក្រុមដែលមិនសូវទទួលបានការយកចិត្តទុកដាក់។ គោលបំណងគួរតែបញ្ចប់នូវច្បាប់ បទដ្ឋាន និងការអនុវត្តទាំងឡាយណា ដែលមានលក្ខណៈរើសអើងចំពោះស្ត្រី និងដណ្តើមប្រយោជន៍ពីជនមានពិការភាព និងមនុស្សស្រលាញ់ភេទដូចគ្នា។ កាន់តែទូទៅជាងនេះ វាក៏នឹងរួមបញ្ចូលផងដែរនូវការបង្កើតការងារកាន់តែល្អប្រសើរ សម្រាប់កម្លាំងការងារក្រៅផ្លូវការដ៏ធំ និងការផ្តល់ការអប់រំដល់យុវជនដែលអាចនាំទៅរកការងារប្រកបដោយផលិតភាព។ នេះជាសិទ្ធិមូលដ្ឋានរបស់មនុស្ស។ ប៉ុន្តែវាក៏បង្កើតនូវករណីធុរកិច្ចដ៏ល្អមួយ ផងដែរ។ សមភាពរបស់ស្ត្រីតែមួយមុខ អាចបន្ថែម ៤.៥ ពាន់ពាន់លានដុល្លារដល់ GDP ប្រចាំឆ្នាំរួមរបស់តំបន់ នៅត្រឹមឆ្នាំ ២០២៥ ស្របពេលដែលការងាររួមបញ្ចូលពិការភាពអាចនឹងធ្វើឱ្យ GDP កើនចន្លោះពី ១ ទៅ ៧ ភាគរយ។

- *ពង្រឹងសមត្ថភាពមនុស្ស តាមរយៈការបង្កើនលទ្ធភាពទទួល បានសុខភាព និងការអប់រំ ប្រកបដោយគុណភាព*។ ត្រូវធ្វើបច្ចុប្បន្នភាពវិធីសាស្ត្របង្រៀន ដោយដាក់បញ្ចូលការអប់រំតាមប្រព័ន្ធឌីជីថល ឱ្យបានកាន់តែច្រើន និងកម្មវិធីសិក្សាដែលសមស្របនឹង តម្រូវការក្នុងឧស្សាហកម្ម។ ឧទាហរណ៍ កម្មវិធីសិក្សា a2i Teacher's Portal របស់ប្រទេសបង់ក្លាដែស បានបំពាក់ ជំនាញឌីជីថលដល់គ្រូបង្រៀនជាងកន្លះលាននាក់។ វាក៏នឹងមានន័យថាជាការប្តេជ្ញាចិត្ត ចំពោះការធានារ៉ាប់រង សុខភាពសកល ផងដែរ។ បណ្តាចំណុចទាំងអស់ខាងលើនឹងតម្រូវឱ្យមានការប្តេជ្ញាចិត្តកម្រិតខ្ពស់ពីរដ្ឋាភិបាលក្នុងការរចនា អនុវត្ត និងផ្តល់ហិរញ្ញប្បទានដល់ប្រព័ន្ធអប់រំ ក៏ដូចជាប្រព័ន្ធ និងសេវាសុខាភិបាល ដើម្បីបង្កើនសមត្ថភាពមនុស្សសម្រាប់ទាំងអស់គ្នា។

**ទី២- ពង្រឹងសន្តិសុខមនុស្ស**។ រដ្ឋាភិបាលអាចដោះស្រាយបញ្ហាឫសគល់មួយចំនួននៃអសន្តិសុខមនុស្ស ខណៈកំពុងការពារផលប៉ះពាល់នៃហេតុការណ៍តក់ស្លុតភ្លាមៗ តាមរយៈ៖

- *ការកែលម្អកិច្ចគាំពារសង្គម*។ ប្រព័ន្ធជាតិគាំពារសង្គមដែលមានលក្ខណៈរួមបញ្ចូល អាចផ្តល់នូវការគាំទ្រជាសាច់ប្រាក់ រួមជាមួយនឹងការបណ្តុះបណ្តាលជំនាញ និងផ្តល់ឱកាសការងារ ជាពិសេសសម្រាប់ "ផ្នែកកណ្តាលដែលមិនទាន់មាន" ពោលគឺសម្រាប់អ្នកនៅក្នុងវិស័យក្រៅផ្លូវការ ឬអ្នករស់នៅលើបន្ទាត់នៃភាពក្រីក្រ ដែលមិនសូវទទួលបានការយកចិត្តទុកដាក់។ ឧទាហរណ៍ ប្រទេសសិង្ហបុរីបានយកចិត្តទុកដាក់ខ្លាំងលើការ សិក្សារៀនសូត្រពេញមួយជីវិត ដើម្បីបង្កើនផលិតភាព នៅក្នុងចំណោម ក្រុមមនុស្សគ្រប់វ័យទាំងអស់។ ប្រទេសនេប៉ាល់ បានបង្ហាញពីវិធីសាស្ត្រដាក់រួមបញ្ចូលគ្នារវាងការផ្ទេរសាច់ប្រាក់ជាមួយនឹងការគាំទ្រផ្នែកជីវភាពរស់នៅ និងការទទួលបានហិរញ្ញប្បទាន និងអត្ថប្រយោជន៍សុខភាពកាន់តែប្រសើរ ដែលអាចជួយបង្កើនភាពធន់នៅក្នុងចំណោមស្ត្រីងាយរងគ្រោះ។

- *ការធានាបាននូវប្រព័ន្ធសុខាភិបាលមានភាពធន់*។ វាពាក់ព័ន្ធនឹងការវិនិយោគនៅក្នុងប្រព័ន្ធជាតិ និងប្រព័ន្ធសហគមន៍ សម្រាប់ការធានារ៉ាប់រងសុខភាពសកល (UHC)។ ជាពិសេសនៅតាមបណ្តាប្រទេសមានប្រជាជនកាន់តែចាស់ នោះប្រព័ន្ធសុខាភិបាលត្រូវការការផ្តល់ហិរញ្ញប្បទានកាន់តែមានចីរភាពថែមទៀត។ វាក៏នឹងអាចឱ្យមានការបញ្ចូលភាពធន់នឹងអាកាសធាតុកាន់តែច្រើន និងការឆ្លើយតបកាន់តែប្រសើរចំពោះជំងឺរាតត្បាត ស្របពេលកំពុងលើកកម្ពស់សមភាព និងបង្កើតដំណោះស្រាយដែលប្រកាន់ខ្ជាប់នូវយេនឌ័រ។ ឧទាហរណ៍ ប្រទេសថៃ បានចាប់ផ្តើមយ៉ាងក្លៀវក្លាលើ UHC ខណៈប្រទេសហ្វីលីពីន ដែលគាំទ្រដោយកំណែទម្រង់ពន្ធថ្នាំជក់ និង

គ្រឿងស្រវឹង បានពង្រីក UHC យ៉ាងមានប្រសិទ្ធភាពទៅដល់ក្រុមងាយរងគ្រោះបំផុតរបស់ប្រទេសនេះ។

- *ការវិនិយោគលើការអភិវឌ្ឍដែលមានព័ត៌មានអំពីហានិភ័យ*។ អាស៊ី និងប៉ាស៊ីហ្វិក ប្រឈមនឹងគ្រោះមហន្តរាយធម្មជាតិយ៉ាងខ្លាំង ហើយត្រូវការការកសាងភាពធន់របស់សហគមន៍កាន់តែរឹងមាំថែមទៀត ជាពិសេសនៅតាមតំបន់ឆ្នេរ ដោយប្រើប្រាស់នវានុវត្តន៍បច្ចេកវិទ្យាទាពេលថ្មីៗឱ្យអស់ពីលទ្ធភាព ។ បណ្តាប្រទេសនានាក៏កំពុងប្រឈមមុខនឹងការធ្វើចំណាកស្រុក និងការផ្លាស់ទីលំនៅបណ្តាលមកពីអាកាសធាតុ ដែលនឹងតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការកម្រិតតំបន់។ ភាគច្រើននៃ បណ្តាប្រទេសដែលប្រឈមនឹងគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរ មានគោលបំណងធានាឱ្យបាននូវការផ្តល់ហិរញ្ញប្បទានឱ្យបានគ្រប់គ្រាន់។ ឧទាហរណ៍ នៅប្រទេសតុងហ្គា រដ្ឋាភិបាលបានបង្កប់នូវភាពធន់នៅក្នុងប្រព័ន្ធរៀបចំផែនការ និងថវិការបស់ក្រសួងហិរញ្ញវត្ថុ ហើយបានបង្កើតនាយកដ្ឋានផ្តល់ហិរញ្ញប្បទាន និង អភិវឌ្ឍភាពធន់។

- *ជំរុញសន្តិសុខស្បៀងអាហារ*។ បណ្តាប្រទេសនានាអាចវិនិយោគលើផលិតភាពកសិកម្ម និងខ្សែចង្វាក់ផ្គត់ផ្គង់កាន់តែរឹងមាំ ស្របពេលកំពង់លើកកម្ពស់ការអនុវត្តការធ្វើកសិកម្មប្រកបដោយចីរភាព។ ឧទាហរណ៍ ប្រទេសសិង្ហបុរី កំពុងសិក្សាស្រាវជ្រាវអំពីវិធីសាស្រ្តបច្ចេកវិទ្យាកសិកម្មថ្មីៗ ដើម្បីផលិតអាហាររបស់ខ្លួនឱ្យបាន ៣០ ភាគ ចេញពីកសិដ្ឋានបញ្ឈរ ត្រឹមឆ្នាំ ២០៣០ ។ ដូចគ្នានេះដែរ នៅក្នុងប្រទេសថៃ និងប៉ាគីស្ថាន បច្ចេកវិទ្យាហិរញ្ញវត្ថុ (fintech) និងកសិ-បច្ចេកវិទ្យា កំពុងប្រើប្រាស់បញ្ញាសិប្បនិម្មិត និងការវិភាគកម្រិតខ្ពស់ ដើម្បីបង្កើនផលិតកម្ម ខណៈកំពុងពង្រីកលទ្ធភាពទទួលបានហិរញ្ញប្បទាន សម្រាប់កសិករខ្នាតតូច។

**ទី៣- ការពារផលប្រយោជន៍កូនចៅជំនាន់ក្រោ**យ។ តំបន់នេះ ត្រូវការការផ្លាស់ប្តូរជាបន្ទាន់ឆ្ពោះទៅរកការអភិវឌ្ឍធន់នឹងអាកាសធាតុ និងអព្យាក្រឹតកាបូន។ កត្តានេះគួរតែគាំទ្រដល់ប្រជាជនដែលកំពុង រងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ស្របពេលមានការទំនួលខុសត្រូវទាំងស្រុងចំពោះអ្នកជំនាន់ក្រោយ។ ចំណុចនេះនឹងមានន័យថា៖

- *ការបង្កើនល្បឿននៃអន្តរកាលថាមពលដ៏ត្រឹមត្រូវ និងព្យាយាមសម្រេចបាននូវការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបស្មើសូន្យ (net zero)* ។ ពង្រឹង និងធ្វើឱ្យបណ្តាញថាមពលមានដំណើរការឡើងវិញ ដោយប្រើអភិក្រមជាប្រព័ន្ធ ដើម្បីឱ្យបណ្តាញថាមពលទាំងនេះអាចដោះការកើនឡើងថាមពលបៃតង បានមកពីព្រះអាទិត្យ ខ្យល់ និងវារីអគ្គិសនី។ នៅក្នុងតំបន់ដែលមានបណ្តាញគ្រប ដណ្តប់យ៉ាងទូលំទូលាយ ការផ្លាស់ប្តូរទៅថាមពលកកើតឡើងវិញ អាចជាបញ្ហាប្រឈ ។ ដំណោះស្រាយក្រៅបណ្តាញអាចជាចម្លើយបណ្តោះអាសន្នរហូតដល់មានការកែលម្អបណ្តាញថាមពលរួចរាល់។ ទន្ទឹមនឹងនេះ កម្មករនៅក្នុងវិស័យឥន្ទនៈ ហ្វូស៊ីល គួរត្រូវបានអនុញ្ញាតឱ្យផ្លាស់ប្តូរទៅរកការងារបៃតង តាមរយៈការរៀនជំនាញឡើងវិញ។ កិច្ចគាំពារសង្គមមានសារសំខាន់ណាស់សម្រាប់អន្តរកាលដ៏ត្រឹមត្រូវ ការកសាងភាពធន់ និងសមត្ថភាពរបស់ជនងាយរងគ្រោះ ដោយសារហេតុការណ៍អាកាសធាតុដែលតក់ស្លុត និងចាប់យកឱកាសឱ្យបាន នៅក្នុងឆាកជីវិតពួកគេ។
- *ការវិនិយោគលើការបន្សាំ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ*។ ខណៈពេលដែលប្រទេសអាស៊ី-ប៉ាស៊ីហ្វិកចំនួន ២៧ បានធ្វើបច្ចុប្បន្នភាពផែនការបន្សាំរបស់ពួកគេ មានតែ ៨ ភាគរយនៃហិរញ្ញប្បទានតំបន់ សម្រាប់ការប្រែប្រួលអាកាសធាតុប៉ុណ្ណោះ ត្រូវបានចាត់ចែងទុកសម្រាប់ការបន្សាំ។ ឧទាហរណ៍ ក្នុងឆ្នាំ២០១៦ប្រទេសស្រីលង្កា បាននាំមុខគេក្នុងការធ្វើផែនការជាតិសម្រាប់ការបន្សាំរបស់ប្រទេសខ្លួន តាមពីក្រោយដោយប្រទេសបង់ក្លាដែស ប៉ាគីស្ថាន និងប៉ាពួញូហ្គីណេ ។ ប៉ុន្តែមានគម្លាតហិរញ្ញប្បទានយ៉ាងខ្លាំង ដែលចំណុចនេះនឹងមានសារសំខាន់ក្នុងការធ្វើឱ្យមានការចូលរួមកាន់តែច្រើនពីវិស័យឯកជន។ យន្តការដោះស្រាយគម្លាតទាំងនេះ រួមបញ្ចូលទាំង គម្រោងហិរញ្ញប្បទានសម្រាប់ការសង្កេតជាប្រព័ន្ធ ឆ្នាំ២០១១ ដែលត្រូវបានសហការបង្កើតឡើងដោយ UNDP, អង្គការឧតុនិយមពិភពលោក និងកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ។

- *ការកំណត់គោលដៅឡើងវិញចំពោះការឧបត្ថម្ភធនទាំងឡាយណាដែលបង្កគ្រោះថ្នាក់ដល់បរិស្ថាន ដើម្បីការពារប្រព័ន្ធអេកូឡូស៊ី និងអភិរក្សជីវៈចម្រុះ* ។ ឧទាហរណ៍ ប្រទេសប៉ាពួញូហ្គីណេ កំពុងធ្វើការវាយតម្លៃលើតម្លៃទីផ្សារនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ស្របពេលដែលស្រីលង្កា កំពុងត្រួតពិនិត្យមើលផលប៉ះពាល់សេដ្ឋកិច្ចនៃការឧបត្ថម្ភធនសម្រាប់ជលផលសមុទ្រ ថាមពល កសិកម្ម ជលវប្បកម្មតាមឆ្នេរសមុទ្រ និងការដឹកជញ្ជូន។

- *ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាន់តែមានទំនួលខុសត្រូវ*។ បន្ទុកលើមនុស្សជំនាន់ក្រោយជាមួយនឹងបំណុល រាំងស្ទះដល់ការអភិវឌ្ឍមនុស្ស។ ការគ្រប់គ្រងបំណុលប្រកបដោយបរិសកម្ម ការកៀរគរប្រាក់ចំណូល និងការវិនិយោគស្របតាម SDG មានសារសំខាន់ខ្លាំងណាស់។ ប្រទេសអាស៊ី-ប៉ាស៊ីហ្វិកមួយចំនួន ដូចជា កម្ពុជា និងនេប៉ាល់ បានទទួលផលប្រយោជន៍ពីការអនុវត្តទាំងនេះ។ ប្រទេសផ្សេងទៀត ដូចជា ឥណ្ឌា សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី និងថៃ បានកាត់បន្ថយហានិភ័យជាមួយនឹងបំណុលរូបិយប័ណ្ណជាតិ។ ឧបករណ៍ប្រកបដោយនវានុវត្តន៍ ដូចជា ការផ្អាកការសងបំណុលបណ្តោះអាសន្នអំឡុងពេលគ្រោះមហន្តរាយ ឬ ‘ការដោះដូរបំណុលសម្រាប់ធម្មជាតិ/SDG’ អាចទាញយកធនធានសម្រាប់ការវិនិយោគលើ SDG បាន។

**ខណៈកំពុងដោះស្រាយបញ្ហាជាប្រព័ន្ធចម្បងៗ ប្រទេសនីមួយៗអាចបង្កើតយុទ្ធសាស្រ្តផ្ទាល់ខ្លួនសម្រាប់គៀគរ និងបែងចែកធនធាន ស្របពេលចរចាលក្ខខណ្ឌដោះដូរចាំបាច់ផ្សេងៗ។**

ទិដ្ឋភាពមួយចំនួននៃការអភិវឌ្ឍមនុស្ស គឺមិនអាចចរចាបានឡើយ ដូចជាសិទ្ធិស្ត្រី និងការប្រព្រឹត្តដោយស្មើភាព និងត្រឹមត្រូវ ក្នុងការទទួលបានធនធាន។ ប៉ុន្តែនឹងមានការអំពាវនាវជាច្រើនមកលើមូលនិធិសាធារណៈ ដែលនឹងតម្រូវឱ្យមានការដោះដូរ និងការសម្របសម្រួល ដោយជៀសមិនផុតឡើយ។ ក្នុងការដោះស្រាយបញ្ហាបែបនេះ រដ្ឋាភិបាលអាចប្រើប្រាស់អភិក្រមផ្តល់បិរញ្ញប្បទានគ្រប់ជ្រុងជ្រោយ ដែលបង្កើនប្រសិទ្ធភាពមូលនិធិសាធារណៈ ជំរុញដល់ហិរញ្ញវត្ថុវិស័យឯកជន និងការវិនិយោគ

ផ្ទាល់ទៅលើវិស័យនានាដែលរំពឹងថានឹងមានផលប៉ះពាល់ខ្លាំងបំផុត ដើម្បីពង្រឹងបរិយាកាសសេដ្ឋកិច្ចអំណោយផលដល់កំណើន ដូច្នេះ ធនធានកាន់តែច្រើនអាចត្រូវបានបញ្ជូនទៅក្នុងការអភិវឌ្ឍមនុស្ស។

## តាមរយៈការពិចារណាឡើងវិញនូវយុទ្ធសាស្ត្រកំណើនរបស់ខ្លួន ប្រទេសនានាអាចទាញប្រយោជន៍ចេញពីកត្តាជំរុញថ្មីៗដល់កំណើន និងការបង្កើតការងារ ដែលជំរុញឱ្យមានការកើនឡើងជាវិជ្ជមាននៃឱកាស វិបុលភាព និងសន្តិសុខ។

**កំណើនសេដ្ឋកិច្ចធ្វើឱ្យមានការស្រមើលស្រមៃ**។ គិតអំពីអ្វីដែលវាអាចធ្វើឱ្យមានភាពខុសគ្នា។ មេដឹកនាំសេដ្ឋកិច្ចពិភពលោកឆ្នាំ១៧០០ មានប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗ លើសតួលេខប្រទេសអាហ្វហ្គានីស្ថាន និងនេប៉ាល់ ក្នុងឆ្នាំ២០១៨ ដែលនេះមានលក្ខណៈប្រៀបធៀបរយៈពេលវែង ដោយផ្អែកលើការលើកឡើងរបស់គម្រោង Maddison ។ នៅត្រឹមឆ្នាំ ១៨៧០ អ្នកនាំមុខគេនៅឆ្នាំនោះ គឺមានប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗ ច្រើនជាងប្រាក់ចំណូលរបស់ប្រទេសបង់ក្លាដែស និង**កម្ពុជា**នាពេលបច្ចុប្បន្នទៅទៀត។ ក្រៅពីនេះ ប្រទេសឥណ្ឌា ឡាវ មីយ៉ាន់ម៉ា ប៉ាគីស្ថាន និងវៀតណាម មានប្រាក់ចំណូលឆ្នាំ២០១៨ តិចជាងចំណូលរបស់អ្នកសេដ្ឋកិច្ចកំពូលៗពិភពលោកកាលពីមួយសតវត្សមុនទៅទៀត។ ខណៈដែលការប្រៀបធៀបទាំងនេះអាចមើលទៅហាក់ដូចជាសោះកក្រោះ ឬមានភាពសម្រាំងពីឫសគល់សេដ្ឋកិច្ច និងប្រវត្តិសាស្ត្រ ឧទាហរណ៍ទាំងនេះ គូសបញ្ជាក់ពីសក្តានុពលដ៏ធំធេងដែលអាចទាញយកប្រយោជន៍បាន ដោយវឌ្ឍនភាពបន្តកើនឡើង តាមរយៈកំណើនប្រកបដោយស្ថិរភាព និងចីរភាព។

**ខណៈកំណើនសេដ្ឋកិច្ចនៅតែចាំបាច់សម្រាប់ការអភិវឌ្ឍមនុស្ស វាត្រូវតែជាប្រភេទនៃកំណើនត្រឹមត្រូវ**។ នៅអាស៊ី និងប៉ាស៊ីហ្វិក ក៏ដូចជាកន្លែងផ្សេងទៀតអញ្ចឹងដែរ កំណើនមានសារសំខាន់ណាស់សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងសម្រាប់ការអភិវឌ្ឍមនុស្ស ដោយបង្កើតឱ្យមានការកើនឡើងជាវិជ្ជមាននៃឱកាស និងវិបុលភាព ទន្ទឹមនឹងនោះក៏រួមចំណែកដល់សន្តិសុខ ផងដែរ។ ប៉ុន្តែលើសពីល្បឿននៃកំណើន វាក៏សំខាន់ផងដែរក្នុងការពិចារណាអំពីលក្ខណៈ និងគុណភាពរបស់វា។ ឧទាហរណ៍ កំណើនអាចនឹងត្រូវបន្តកើនឡើង ជាមួយនឹងការយកចិត្តទុកដាក់តិចតួចលើសិទ្ធិមនុស្ស ធ្វើឱ្យមនុស្សធ្វើការច្រើនម៉ោង តែទទួលបានប្រាក់ឈ្នួលមិនគ្រប់គ្រាន់ និងលក្ខខណ្ឌការងារមិនល្អ ឬប្រកបដោយគ្រោះថ្នាក់។ ហើយប្រសិនបើផលប្រយោជន៍នៃកំណើន ត្រូវបានចាប់យកជាចម្បងដោយក្រុមអ្នកមានអំណាច នៅក្នុងសេដ្ឋកិច្ចផ្លូវការ នោះកំណើនអាចបណ្តាលឱ្យមានទ្វិកនិយមសេដ្ឋកិច្ច ដែលប្រជាជនភាគច្រើនត្រូវបានគេទុកចោល នៅក្នុងវិស័យក្រៅផ្លូវការ ជាហេតុធ្វើឱ្យងាយរងគ្រោះទៅនឹងហេតុការណ៍តក់ ស្លុតខាងក្រៅ។ ជាមួយគ្នានេះ កំណើនឆាប់រហ័ស ជារឿយៗកើតឡើងជាមួយនឹងស្លាកស្នាមបរិស្ថានធំៗ។

**យុទ្ធសាស្ត្រកំណើនដ៏រឹងមាំនៅក្នុងយុគសម័យថ្មីនេះនឹងតម្រូវឱ្យមានអភិក្រមថ្មីឆ្ពោះទៅរកកំណើនដឹកនាំដោយការនាំចេញ**។ ប្រទេសជាច្រើននឹងសម្លឹងរកមើលកំណើនដឹកនាំដោយការនាំចេញ ដោយភ្ជាប់ជាមួយនឹងពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស (FDI) និងបច្ចេកវិទ្យា។ ប៉ុន្តែជាមួយនឹងលក្ខខណ្ឌទីផ្សារខាងក្រៅកាន់តែមានភាពប្រកួតប្រជែង នោះការយកចិត្តទុកដាក់ឱ្យបានល្អិតល្អន់លើការប្រកួតប្រជែង និងការធ្វើពិពិធកម្ម កាន់តែមានសារសំខាន់ខ្លាំងឡើងថែមទៀត។ ទន្ទឹមនឹងនេះ កម្មករក៏គួរតែទទួលបានអត្ថប្រយោជន៍ពីគោលនយោបាយប្រាក់ឈ្នួលសមរម្យ និងសិទ្ធិការងារ រួមជាមួយនឹងការអភិវឌ្ឍជំនាញ និងការបណ្តុះបណ្តាល ផងដែរ។ ការភ្ជាប់ឧស្សាហកម្មនាំចេញ ជាពិសេសតំបន់ពាណិជ្ជកម្មសេរី ជាមួយនឹងសេដ្ឋកិច្ចក្នុងស្រុក អាចជំរុញឧស្សាហកម្ម និង សេវាកម្មក្នុងស្រុក។ ខណៈដែលប្រទេសមួយចំនួនដូចជាបង់ក្លាដែស **កម្ពុជា** ហ្វីលីពីន និងវៀតណាម បានឈានទៅមុខក្នុងទិសដៅនេះ វានឹងមានឱកាសលូតលាស់បន្ថែមទៀត។

**ទន្ទឹមនឹងនេះ ប្រទេសទាំងអស់អាចបង្កើនសក្តានុពលទីផ្សារក្នុងស្រុកជាអតិបរមា**។ ចំណុចនេះមានសារសំខាន់ជាពិសេសនៅតាមបណ្តាប្រទេសធំៗ។ រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន អាចដំណើរការពាណិជ្ជកម្មក្នុងស្រុកដោយរលូន តាមរយៈការធ្វើសុខដុមនីយកម្មបទប្បញ្ញត្តិច្បាប់ និងការកែលម្អការដឹកជញ្ជូន ស្របពេលជាមួយគ្នានេះលើក ទឹកចិត្តឱ្យមានជំនាញឯកទេសនៅថ្នាក់ក្រោមជាតិ ជាពិសេសទំនិញ ឬ សេវាកម្ម។ នៅតាមបណ្តាប្រទេសអាស៊ី-ប៉ាស៊ីហ្វិកជាច្រើន កម្មករភាគច្រើននៅតែស្ថិតនៅលើបរិមណ្ឌលនៃសេដ្ឋកិច្ចផ្លូវការ ជាមួយនឹងការគាំទ្រ ស្ថាប័ន កិច្ចគាំពារសង្គម ឬឱកាសទទួលការបណ្តុះបណ្តាល តិចតួចប៉ុណ្ណោះ។ រដ្ឋាភិបាលអាចធ្វើឱ្យប្រសើរឡើងនូវផលិតភាព និងសិទ្ធិរបស់កម្មករ តាមរយៈការអនុញ្ញាតឱ្យមនុស្សកាន់តែច្រើនចូលរួមនៅក្នុងកម្លាំងការងារផ្លូវការ ទន្ទឹមនឹងនេះក៏កែលម្អជីវភាពក្នុងវិស័យក្រៅផ្លូវការ ផងដែរ។ ការលុបបំបាត់របាំងយេនឌ័រ និងធានានូវឱកាសស្មើគ្នាសម្រាប់ស្ត្រី ក៏មាន សារសំខាន់ខ្លាំង ផងដែរ។ លើសពីកម្រិតនៃការរក្សាសិទ្ធិជាមូលដ្ឋានរបស់ ប្រជាជនពាក់កណ្តាលក្នុងតំបន់ការផ្លាស់ប្តូរនេះផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងធំធេង។ វាជួយឱ្យប្រទេសនានាអាចទាញយកមកប្រើនូវធនធានមនុស្សដែលមានទេពកោសល្យតែមិនទាន់ប្រើប្រាស់ ជាមួយនឹងជំនាញ និងស្មារតីសហគ្រិន។

**នៅអាស៊ី និងប៉ាស៊ីហ្វិក ប្រទេសនានាអាចចាប់យកឱកាសលើវិស័យសំខាន់ៗចំនួនបួន។**

- *កម្មន្តសាលកម្ម* - ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ ការចូលរួមចំណែកពីកម្មន្តសាលកម្ម នៅក្នុងសេដ្ឋកិច្ចជាតិ បាននិងកំពុងធ្លាក់ចុះ ខណៈដែលប្រទេសជាច្រើនបានកាត់បន្ថយឧស្សាហកម្មជាបន្តបន្ទាប់។ ការធ្វើបែប នេះ អាចត្រូវបានចាត់ទុកថាជាការធ្វើឡើងមុនកាលកំណត់។ កម្មន្តសាលកម្ម អាចមានផលប៉ះពាល់ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ ដូចជាស្តង់ដារការងារធូររលុង ឬមានភាពគ្រោះថ្នាក់ខាងបរិស្ថាន ឬការបង្កើតតំបន់មានការហ៊ុមព័ទ្ធជុំវិញ។ ទោះបីជាយ៉ាងនេះក្តី វានៅតែអាចនាំមកនូវអត្ថប្រយោជន៍ជាច្រើន ជាមួយនឹងការផ្សារភ្ជាប់ទៅនឹងពាណិជ្ជកម្ម និងនវានុវត្តន៍។ សម្រាប់ប្រទេសជាច្រើននៅក្នុងតំបន់ឧស្សាហូបនីយកម្ម នៅតែផ្តល់ក្តីសង្ឃឹម ជានិច្ច ទោះបីជាវាអាចទាមទារឱ្យដើរតាមផ្លូវឧស្សាហកម្ម ផ្សេងៗគ្នាក៏ដោយ។

- *សេវាកម្ម និងកសិកម្ម* - ការប្រែប្រួលផ្នែកបច្ចេកវិទ្យា បាននិងកំពុង

ធ្វើឱ្យមានភាពមិនច្បាស់ពីភាពខុសគ្នាបែបប្រពៃណី រវាងសេវាកម្ម និងកម្មន្តសាលកម្ម និងកសិកម្មផងដែរ។ ដើម្បីបង្កើន ផលិតភាពឱ្យបានជាអតិបរមា “កសិកម្ម ៣.០” ប្រើប្រាស់អស់ពីលទ្ធភាពនូវ GPS និងបច្ចេកវិទ្យាឌីជីថល និងជីវគីមីផ្សេងទៀត ហើយពឹងផ្អែកកាន់តែខ្លាំងទៅលើធាតុចូលពីកម្មន្តសាលកម្ម និងពីអ្នកផ្តល់សេវា។ ដូច្នេះធ្វើឱ្យវាមានឱកាសនៅត្រង់ចំណុចប្រសព្វនៃវិស័យទាំងបីនេះ។

- *សេដ្ឋកិច្ចបៃតង ខៀវ និងស្វាយ* - នៅក្នុងសេដ្ឋកិច្ចបៃតង សេចក្តីត្រូវការឱ្យកាត់បន្ថយកាបូន បង្កើតឱកាសសម្រាប់នវានុវត្តន៍នៅក្នុងខ្សែចង្វាក់តម្លៃ និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងការបន្សាំ ឧទាហរណ៍ ដូចជា ឱកាសសម្រាប់យន្តការកែសម្រួលព្រំដែនកាបូនរបស់សហភាពអឺរ៉ុប (EU’s Carbon Border Adjustment Mechanism) ។ នៅក្នុងសេដ្ឋកិច្ចខៀវ ធនធានសមុទ្រដ៏សម្បូរបែបរបស់តំបន់នេះ អាចត្រូវបានធ្វើឱ្យប្រសើរឡើង និងកាន់តែមានចីរភាព តាមរយៈបច្ចេកវិទ្យាថ្មីៗ និងការវិនិយោគ ដែលមានសារសំខាន់ជាពិសេសសម្រាប់បណ្តារដ្ឋកោះតូចៗកំពុងអភិវឌ្ឍ ក៏ដូចជាសម្រាប់បណ្តាលប្រទេសដែលមានឆ្នេរសមុទ្រវែង ផងដែរ។ នៅក្នុងសេដ្ឋកិច្ចស្វាយ(ការថែទាំ) ក្មេងស្រី និងស្ត្រីជាធម្មតាចំណាយពេលច្រើនម៉ោងលើការថែទាំ និងការងារផ្ទះដោយមិនមានប្រាក់ខែនោះទេ។ ប៉ុន្តែគួរតែមានឱកាសសម្រាប់ការធ្វើពាណិជ្ជកម្ម ឬការផ្តល់ដោយរដ្ឋ ដែលមិនលំអៀងដោយយេនឌ័រ ហើយវានឹងធ្វើឱ្យស្ត្រីមានសេរីភាពចូលរួមនៅក្នុងសេដ្ឋកិច្ច និងនយោបាយកាន់តែច្រើន។

- *បច្ចេកវិទ្យាស្រាវជ្រាវរកឃើញថ្មីៗ* - ការជឿនលឿនផ្នែកបច្ចេកវិជ្ជាយ៉ាងឆាប់រហ័សនៅក្នុងវិស័យជាច្រើនកំពុងផ្លាស់ប្តូរឧស្សាហកម្មកម្មន្តសាល កាត់បន្ថយរបាំងចូល និងអនុញ្ញាតឱ្យក្រុមហ៊ុននានានៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ផលិតផលិតផលមានតម្លៃកាន់តែខ្ពស់ និងកាន់តែមានលក្ខណៈស្មុគស្មាញ ដូចជា រថយន្តអគ្គិសនី អាគុយផ្ទុក បន្ទះស្រូបពន្លឺព្រះអាទិត្យ ឱសថកម្ម ឬទូរស័ព្ទដៃទំនើបៗ។ បន្ថែមពីលើការរៀបចំដំឡើង ក្រុមហ៊ុនកំពុងដាក់បញ្ចូលនៅក្នុងកម្មន្តសាលសម្រាប់ការផលិតគ្រឿងបន្លាស់ និងធ្វើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ហើយបញ្ជូនបន្តទៅក្នុងសេវាកម្មដែលបង្កើតតម្លៃបន្ថែម ត្រូវបានបង្កើតឡើងដោយឧស្សាហកម្ម ដែលទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថលកំពុងរីករាលដាលពេញវិស័យសេវាកម្ម។

**វិស័យទាំងអស់នេះគួរតែជួយបំពេញបំណងប្រាថ្នារបស់យុវជនជំនាន់ក្រោយ**។ កម្មន្តសាលកម្ម នឹងនៅតែជាប្រភពដ៏សំខាន់នៃកំណើន និងការងារ សម្រាប់យុវជនក្នុងប្រទេសដែលមានចំណូលទាបដល់មធ្យម ជាពិសេសនៅក្នុងវិស័យ បច្ចេកវិទ្យាធុនស្រាល និងមធ្យម។ ប៉ុន្តែអ្នកផលិតក៏ត្រូវងាកទៅរកជម្រើសកាបូនទាប ដែលវានឹងបន្ថែមបន្ទុកចំណាយ និងភាពមិនប្រាកប្រជា។ ឱកាសសម្រាប់ការងារនឹងអាស្រ័យលើសមាសភាពនៃតម្រូវការ អត្រានៃការវិវត្តផ្នែកបច្ចេកវិទ្យា និងគុណភាពនៃជំនាញកម្លាំងពលកម្ម។ កម្មករមួយចំនួនក៏អាចត្រូវបានគេរំពឹងថានឹងធ្វើចំណាកស្រុកទៅក្រៅប្រទេសផងដែរ ដើម្បីប្រើប្រាស់សក្តានុពលរបស់ពួកគេឱ្យអស់ពីលទ្ធភាព។

**ទន្ទឹមនឹងវិធានការផ្តោតលើប្រជាជន អាទិភាពគោលនយោបាយមួយចំនួនដែលយកចិត្តទុកដាក់លើវិស័យ ដូចជា ការអប់រំ និងជំនាញលេចជារូបរាងឡើងដើម្បីការពារកំណើន និងជំរុញការបង្កើតការងារ**។ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព បង្កើតបានជាមូលដ្ឋានគ្រឹះ។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចទាមទារការមានវិន័យសារពើពន្ធ និងផ្តល់ភាពបត់បែនក្នុងការបន្តធ្វើកំណែទម្រង់។ ដើម្បីអាចចូលទៅក្នុងទីផ្សារបង្កើតឡើងដោយក្រុមវណ្ណៈកណ្តាលដែលកំពុងរីកចម្រើន នៅក្នុងតំបន់ រដ្ឋាភិបាល និងឧស្សាហកម្ម នឹងត្រូវយកចិត្តទុកដាក់ខ្លាំងឡើងថែមទៀតលើកត្តាខាងក្រៅ ពោលគឺស្វែងរកការធ្វើឱ្យទំនាក់ទំនងពាណិជ្ជកម្មក្នុងតំបន់ឱ្យកាន់តែស៊ីជម្រៅ ទន្ទឹមនឹងនេះក៏ជំរុញការតភ្ជាប់នៅកម្រិតសកល ផងដែរ។ ការកែលម្អ ដំណើរការធុរកិច្ច ការកែទម្រង់សហគ្រាសរដ្ឋ និងការជំរុញការចាប់ផ្តើមអាជីវកម្ម និងសហគ្រិនភាព នៅតែមានសារសំខាន់សម្រាប់ការប្រកួតប្រជែងទីផ្សារ។ យុទ្ធសាស្ត្រឧស្សាហកម្មបច្ចេកវិទ្យា គួរលើកកម្ពស់ នវានុវត្តន៍ ផ្តល់អាទិភាពដល់ការណែនាំធ្វើទីផ្សារ អនុញ្ញាតឱ្យក្រុមហ៊ុនចាកចេញ និងពិចារណាអំពីផលប៉ះពាល់បរិស្ថាន។

## ដើម្បីជំរុញស្មារតីនៃការផ្លាស់ប្តូរ និងដាក់ចេញនូវគំនិតថ្មីៗទៅក្នុងការអនុវត្ត ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំង ទៅលើនយោបាយនៃកំណែទម្រង់ និងប្រសិទ្ធភាពនៃប្រព័ន្ធចែកចាយ។

អនុសាសន៍ខាងក្រោមនេះមានឥទ្ធិពលនៅពេលមានសកម្មភាពអនុវត្តវាតែប៉ុណ្ណោះ។ 'ការបង្កើតអនាគតរបស់យើង' ប្រកបដោយបរិសកម្ម នឹងត្រូវការការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងទៅលើនយោបាយនៃការធ្វើកំណែទម្រង់ និងការរៀបចំយន្តការចែកចាយប្រកបដោយប្រសិទ្ធិភាព ដែលជាកិច្ចការកាន់តែពិបាកអនុវត្ត នៅគ្រាដែលមានលទ្ធិប្រជាធិបតេយ្យដើរថយក្រោយ ការកើនឡើងនៃប្រជានិយម និងការបែងខ្ញែកគ្នា ព្រមទាំងការធ្លាក់ចុះជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើស្ថាប័នសាធារណៈ។ អ្នកបង្កើតគោលនយោបាយ ក៏ត្រូវចូលរួមជាមួយប្រព័ន្ធផ្សព្វផ្សាយសង្គម និងដោះស្រាយការបំពុលព័ត៌មាន ផងដែរ។

ការលោតផ្លោះពីយុទ្ធសាស្ត្រមួយទៅជាសកម្មភាពក៏នឹងទាមទារឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតក្នុងចំណោមអ្នកដឹកនាំ និងសហគមន៍ ព្រមទាំងមានស្ថាប័នកាន់តែរឹងមាំសម្រាប់ការអនុវត្ត។ ការផ្លាស់ប្តូរពិតប្រាកដនឹងពឹងផ្អែកលើការពិចារណាយ៉ាងប្រុងប្រយ័ត្ន និងការយកចិត្តទុកដាក់លើការអនុវត្តជាក់ស្តែង និងលើសមត្ថភាព ដើម្បីធ្វើឱ្យមានការអន្តរាគមន៍ទាន់ពេលវេលាស្របតាមយុទ្ធសាស្ត្រ។ ដូចបានបង្ហាញក្នុងអំឡុងពេលជំងឺរាតត្បាត អភិបាលកិច្ចត្រូវតែសម្របយ៉ាងឆាប់រហ័សទៅនឹងតម្រូវការនៃស្ថានការណ៍នៅពេលនោះ និងអនុវត្តកិច្ចអន្តរាគមន៍ដែលចាំបាច់។

អភិបាលកិច្ចដែលសមស្របសម្រាប់អនាគត ឆ្លុះបញ្ចាំងពីបំណងប្រាថ្នាមួយ ប៉ុន្តែមិនមែនជាភាពស្រមើស្រមៃនោះទេ។ វាគឺជាដំណើរមួយ ដែលជាដំណើរការនៃការសិក្សា ការពិសោធន៍ និងការកែលម្អជាបន្ត។ ខណៈពេលដែលតំបន់នេះមានមោទនភាពអំពីវិសាលគមនៃរចនាសម្ព័ន្ធអភិបាលកិច្ច នោះទាំងអស់គ្នានឹងទទួលបានអត្ថប្រយោជន៍ពីយន្តការដែលមានជំនាញក្នុងការអនុវត្តកិច្ចអន្តរាគមន៍ចាំបាច់ ដើម្បីទាញយកឱកាសដែលនឹងកើតឡើងនៅថ្ងៃស្អែក។

ប្រព័ន្ធអភិបាលកិច្ចសមស្របនាពេលអនាគតនឹងត្រូវការ លក្ខណៈសំខាន់បី៖

- *ការស្មានទុកជាមុន* - ការប្រមើមើលពីបញ្ហាប្រឈម ឱកាស និងការប្រែប្រួលបរិយាកាស ដែលអាចកើតមានឡើង តាមរយៈការជ្រើសរើស ទៅលើសញ្ញាជាច្រើន និងការគិតគូរពីសេណារីយ៉ូផ្សេងៗ។

- *លទ្ធភាពបន្សាំ* - ការអាចបន្សាំទៅនឹងព័ត៌មានថ្មីៗ ការផ្លាស់ប្តូរលក្ខខណ្ឌ ឬការផ្លាស់ប្តូរអាទិភាព តាមរយៈអភិក្រមដដែលៗ ផ្អែកលើមិនមែនគ្រាន់តែការរៀនសូត្រមួយមុខប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការមិនរៀនសូត្រផងដែរ។

- *ភាពរហ័សរហួន* - ការឆ្លើយតបយ៉ាងឆាប់រហ័សចំពោះព័ត៌មានថ្មីៗ ឬព្រឹត្តិការណ៍ដែលមិនរំពឹងទុក ដោយការកំណត់ទិសដៅធនធានឡើងវិញ ផ្អែកលើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយទីភ្នាក់ងារនានា និងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការសម្រេចចិត្តចរិកា។

**ហើយនៅចំពោះមុខទិចលភាព វាក៏សំខាន់ផងដែរក្នុងការជំរុញស្មារតីនៃការផ្លាស់ប្តូរតាមរយៈ៖**

- *ការបណ្តុះឆន្ទៈនយោបាយ* - អ្នកដឹកនាំនយោបាយ ឬអ្នកធ្វើការសម្រេចចិត្ត ប្រហែលជាមិនប្រាកដក្នុងចិត្តអំពីការផ្សងព្រេងនៅក្នុងទិសដៅថ្មីៗ ឬមានអារម្មណ៍ថាពួកគេខ្វះចំណេះដឹង និងសមត្ថភាពក្នុងការបង្កើតផែនការថ្មីៗ។ ក្នុងករណីនេះ ពួកគេអាចទទួលបានអត្ថប្រយោជន៍ពី 'ការអមជាយុទ្ធសាស្ត្រ' ដោយទីប្រឹក្សាមានសមត្ថភាព និងដាក់ចំណុចទីតាមជំនាញយ៉ាងល្អ ដែលអាចផ្តល់ដំបូន្មានប្រកបដោយចីរភាព និងផ្អែកលើភស្តុតាង។

- *ភាពជាអ្នកដឹកនាំដែលសហការ* - វានឹងចាំបាច់ដើម្បីតភ្ជាប់ភាពចន្លោះ និងបង្កើតឱ្យមានការឯកភាពគ្នាតែមួយជុំវិញគោលនយោបាយសំខាន់ៗ។ វាអាចផ្អែកលើការសម្រុះសម្រួលខាងក្នុងដើម្បីដោះស្រាយវិវាទ និងសម្របសម្រួលកិច្ចសន្ទនារវាងក្រុមដែលប្រកួតប្រជែងគ្នា។

- *ការចូលរួមរបស់ពលរដ្ឋ* - ភាពជាពលរដ្ឋសកម្ម និងភាពជាដៃគូពហុភាគី អាចធានាបាននូវទស្សនវិស័យចម្រុះ លើកកម្ពស់ការរួបរួមសង្គម និងដោះស្រាយបញ្ហានៅថ្នាក់មូលដ្ឋាន។ បន្ថែមពីលើទម្រង់នៃការចូលរួមបែបប្រពៃណី តឡូវនេះប្រជាពលរដ្ឋអាចចូលរួមតាមរយៈវេទិកានានាសម្រាប់អភិបាលកិច្ចអេឡិចត្រូនិក និងនវានុវត្តន៍ ។

***

**ប្រទេសនីមួយៗនឹងជ្រើសរើសដំណោះស្រាយរបស់ខ្លួន ប៉ុន្តែទាំងអស់គ្នានឹងទទួលបានអត្ថប្រយោជន៍ពីអភិក្រមមានលក្ខណៈរួមបញ្ចូលគ្នា**។ កំណើនសេដ្ឋកិច្ចឆាប់រហ័សនឹងមិនគ្រប់គ្រាន់ទេ ហើយក៏មិនលើកកម្ពស់ការអភិវឌ្ឍមនុស្ស ដោយការបាត់បង់កំណើនដែរ។ លើសពីនេះ គ្មានយុទ្ធសាស្ត្រណានឹងទទួលបានជោគជ័យ ដោយគ្មានការអនុវត្តសកម្មភាពឆ្លើយតបនឹង វានោះទេ។ ជាការជំនួស ប្រទេសនានាអាចប្រើប្រាស់ធាតុទាំងបីនៃអភិក្រមដែលបានស្នើឡើង៖ ការបញ្ជ្រាបការអភិវឌ្ឍមនុស្ស ការពិចារណាឡើងវិញទៅលើកំណើន និងការធ្វើឱ្យមានការផ្លាស់ប្តូរ។ **កម្ពុជា**កំពុងស្ថិតក្នុងរបត់ប្រវត្តិសាស្ត្រមួយ ដែលកំពុងរំកិលខ្លួនដើម្បីចាកចេញពីប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុត (LDCs) និងដាក់ចំនុចដៅអភិវឌ្ឍន៍ដ៏មហិច្ឆតារបស់ខ្លួនឱ្យក្លាយជាប្រទេសមានចំណូលលើមធ្យមត្រឹមឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០ ដូចបានបញ្ជាក់ក្នុង**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ២០២៤-២០២៨**។ កំណើនសេដ្ឋកិច្ចក្នុងពេលថ្មីៗពិតជាគួរឱ្យកត់សម្គាល់ ប៉ុន្តែហាក់ដូចជាមិនទាន់គ្រប់គ្រាន់ដើម្បីសម្រាប់មហិច្ឆតាដ៏ធំទាំងនោះនៅឡើយទេ។ មានឱកាសដើម្បីពង្រឹងកំណើនសេដ្ឋកិច្ចឱ្យកាន់តែខ្លាំងនិងមានភាពធន់បន្ថែមទៀត ដោយការផ្តល់អាទិភាពលើការអភិវឌ្ឍន៍មនុស្ស ស្របពេលនឹងការបន្តយកចិត្តទុកដាក់លើបញ្ហាបរិស្ថាន និងការថែទាំភពផែនដីសម្រាប់មនុស្សជំនាន់នេះនិងជំនាន់ក្រោយ។

*«តំបន់អាស៊ីប៉ាស៊ីហ្វិកមានឥទ្ធិពលយ៉ាងខ្លាំងលើការសម្រេចបាននិងចក្ខុវិស័យនៃការអភិវឌ្ឍន៍របស់ពិភពលោក។ យើងរំពឹងថារបាយការណ៍នេះមិនត្រឹមតែជួយឱ្យយើងអាចស្រមៃឡើងវិញពីយុទ្ធសាស្ត្ររបស់យើង ដើម្បីធានាឱ្យមានភាពធន់សម្រាប់ការអភិវឌ្ឍន៍មនុស្សក្នុងតំបន់ប៉ុណ្ណោះទេ ហើយក៏ជាការលើកទឹកចិត្តសម្រាប់តំបន់ផ្សេងទៀត និងបណ្តាលប្រទេសផ្សេងទៀតផងដែរ» លោក Achim Steiner ប្រធានកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។*

តំណភ្ជាប់ទៅកាន់របាយការណ៍ពេញ: https://www.undp.org/asia-pacific/publications/making-our-future-new-directions-human-development-asia-and-pacific

**United Nations Development Programme**
One United Nations Plaza
New York, NY 10017

www.undp.org

© UNDP 2024